**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៦

**សេចក្តីផ្តើម :**

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៥ :<br>១.សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល<br>២.សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៧ ស្តីពីប្រព័ន្ធធ្វងកាត់គយនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីកិច្ចសម្រួលការដឹកជញ្ជូនឆ្លងកាត់ទំនិញ<br>៣.សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារ ដើម្បីអនុវត្តកញ្ចប់ទី៦ នៃការប្តេជ្ញាបើកចំហរសេវាហិរញ្ញវត្ថុ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវា | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក<br>- ប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យសិក្សាស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាសម្រាប់នីតិកាលទី៤<br>- ទទួលសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ ពីរដ្ឋសភា និងបានចម្លងចែកជូនគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា<br>- ធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៣៧ច្បាប់ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ៤.សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣<br>៥.សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន ពិធីសារស្តីពីការបង្កើត និងការអនុវត្តបញ្ជរតែមួយអាស៊ាន និងពិធីសារស្តីពីក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន<br>- គណៈកម្មការទី២ ប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់<br>- គណៈកម្មការទី៨ ប្រជុំជាមួយតំណាងក្រសួងសុខាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ។ | - បានផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់សរុបចំនួន១៦លើក អ្នកចូលរួមចំនួន៣៧៨នាក់ និងរៀបចំសាល បម្រើសេវាភេសជ្ជៈសរុបចំនួន០៩លើក មានអ្នកចូលរួមចំនួន១៩២នាក់<br>- បានថតចម្លងឯកសារ និងចងក្រងធ្វើសៀវភៅសរុបចំនួន២០សំណើ ស្មើ២.៥៤៩ច្បាប់ ធ្វើសៀវភៅ១៨ក្បាលអស់ក្រដាសសរុបចំនួន៥៩.៤២៦សន្លឹក<br>- ការពារ និងរៀបចំសណ្តាប់ធ្នាប់នៅពេលប្រជុំដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៧៧នាក់ ស្មើនឹង០៦លើក<br>- ធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា បញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បានស្រាវជ្រាវអំពីនីតិវិធីក្នុងការតាក់តែងច្បាប់របស់សភាប្រទេសទាំង១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៦លើក ត្រួតពិនិត្យប្រព័ន្ធសំឡេង ម៉េក្រូហ្វូន កាមេរ៉ាវីដេអូសុវត្ថិភាពចំនួន១២៩លើក ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន៣១លើក បង្ហោះលើគេហទំព័រព្រឹទ្ធសភា និងផលិតជា Video online ចំនួន២៥លើក<br>- បានរៀបចំបែបបទ និងធ្វើកំណត់ហេតុ នៃកិច្ចប្រជុំអន្តរគណៈកម្មការ ជាមួយក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី |

| | |
|---|---|
| | ពិនិត្យលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់<br>- សុន្ទរកថាបិទក្នុងអង្គសិក្ខាសាលាស្តីពី "សេចក្តីផ្តើមនៃការតាក់តែងច្បាប់ ឯកសារយោង និងបច្ចេកទេស" ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| + សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ពីដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នៅខេត្តកំពង់ចាម<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយប្រធានក្រុមប្រឹក្សាខេត្ត ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងតាមដានលទ្ធផលក្រោយរៀបចំវេទិកា នៅខេត្តព្រៃវែង<br>- អញ្ជើញចុះតាមដានលទ្ធផលការងារ និងសិក្សាស្រាវជ្រាវប្រមូលព័ត៌មានទាក់ទងនិងការចុះឈ្មោះបោះឆ្នោត និងជំរុញការធ្វើអត្តសញ្ញាណប័ណ្ណគំរូថ្មី ព្រមទាំងអនុវត្តកម្មវិធីអភិវឌ្ឍភូមិ-ឃុំមានសុវត្ថិភាព នៅមូលដ្ឋានចំនួន០២លើក ដោយមានសមាជិកចូលរួមចំនួន១១រូប ។ | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចុះទៅតាមដានលទ្ធផលការងារ និងសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ព្រមទាំងស្វែងយល់អំពីការអនុវត្តច្បាប់នៅតាមបណ្តាខេត្តនានាចំនួន ២០នាក់ ស្មើនឹង០២ច្បាប់ ។ |

**៣.មុខងារតំណាង :**

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីបុណ្យខួបគំរប់៤ឆ្នាំ នៃការយាងចូលទិវង្គត ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ " ព្រះបរមរតនកោដ្ឋ " នៅព្រះធម្មសាលាក្នុងបរិវេណព្រះឧបោសថរតនារាម ព្រះកែវមរកត ព្រះបរមរាជវាំង<br>+ អញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាស្ត្រីស្តីពី"វឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ"<br>+ អញ្ជើញជាអធិបតីក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១២ ទី១៣ នៅវត្តកប់ស្រូវ វត្តមុនីប្រសិទ្ធិវង្ស វត្តច័ន្ទគិរីវង្ស និងវត្តព្រែកប្រាំង សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមជាកិត្តិយសអបអរសាទរពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ខណ្ឌ រាជធានី និងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាព សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ មន្ត្រីគ្រប់គ្រងស្ថានីយ៍បូមទឹកទំនប់កប់ស្រូវ និងទំនប់ទួលសំពៅ អ្នកប្រកបរបរត់ម៉ូតូឌុប ម៉ូតូកង់បី | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីភាព ក្នុងពិធីផ្សេងៗសរុបចំនួន២៥៦លើក<br>- បានសហការរៀបចំវេទិកាស្តីពីវឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ<br>- បានធ្វើកំណត់បង្ហាញ និងបញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី និងតម្កល់ទុកមិនចាត់ការចំនួន០២ករណី<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងចុះស្រាវជ្រាវព័ត៌មាន ចុះបេសកកម្មរៀបចំវេទិកា ចុះតាមដានលទ្ធផលក្រោយការរៀបចំវេទិកា និងពិធីសំណេះសំណាលផ្សេងៗ អមដំណើរក្រុមសមាជិកា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ ទី៣ ទី៤ ទី៨ ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករដ្ឋបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ មេប៉ុស្តិ៍ចំនួន០៤លើក នៅខណ្ឌទួលគោក ច្បារអំពៅ សែនសុខ និងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>- បានចុះប្រមូលព័ត៌មានចំនួន១៤ឃុំ ក្នុងខេត្តកំពង់ចាម និងចុះស្រាវជ្រាវពីបញ្ហាប្រឈមសំណូមពរថ្មីៗ នៅស្រុកកៀនស្វាយ និងស្រុក |

| | |
|---|---|
| នៅខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌព្រែកព្នៅ ខណ្ឌឬស្សីកែវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ<br>+ អញ្ជើញពិនិត្យទំនប់សណ្ដោរស្ទឹងព្រែកត្នោត និងសួរសុខទុក្ខក្រុមការងាររបស់ក្រសួងធនធានទឹក និងឧតុនិយមដែលប្រចាំការនៅកន្លែងទំនប់បាក់ ក្នុងភូមិសាលា សង្កាត់ទៀន ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>+ អញ្ជើញសួរសុខទុក្ខលោកព្រឹទ្ធាចារ្យ ឆេង ផុន អតីតប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលកំពុងព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្រ<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅស្រុកអង្គស្នួល ខេត្តកណ្ដាល<br>- សមាជិកគណៈកម្មការទី១ បានអញ្ជើញធ្វើបទបង្ហាញអំពីតួនាទី ភារកិច្ច របស់ព្រឹទ្ធសភា ជូនលោកគ្រូ អ្នកគ្រូ និងនិស្សិតមកពីសាកលវិទ្យាល័យ Southeast Asia និងវិទ្យាល័យមិត្តភាពកម្ពុជា-វៀតណាម នៅខេត្តសៀមរាប<br>- ប្រធានគណៈកម្មការទី៧ បានជួយទិញអង្ករសែនក្រអូបពីក្រុមហ៊ុន Trust Our Trade ចំនួន០១តោន និងធ្វើបទបង្ហាញជូនមន្ត្រីស្រាវជ្រាវសម្រាប់ដំណាក់កាលទី២ ចំនួន០៨នាក់<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចុះជួប | សំឡូត ខេត្តបាត់ដំបង និងចុះបេសកកម្មតាមដានលទ្ធផល និងឈ្វេងយល់ពីវឌ្ឍនភាពក្រោយវេទិកា នៅខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តព្រះវិហារ<br>- បានចុះលេខចុងសន្លឹក សរសេរមាតិកា រៀបចំឯកសារ របស់ថ្នាក់ដឹកនាំ គណៈកម្មការទាំង១០ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥ប្រអប់ និង៥៥៩សំណុំ<br>- បានរៀបចំពិធីសែនក្រុងពាលី សូត្រមន្ត និង ដង្ហែអង្គកឋិនទៅកាន់វត្តមុនីប្រសិទ្ធិវង្ស ស្ថិតនៅក្នុងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងវត្តប្រាំបីមុំ ខេត្តតាកែវ<br>- បានចុះសួរសុខទុក្ខនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១នាក់<br>- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៣១នាក់ ស្មើនឹង៤១ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៣នាក់ ស្មើនឹង០៣ច្បាប់<br>- បានថតចម្លងឯកសារចំនួន២១សំណើ អស់ក្រដាសចំនួន៣,៦៣៨សន្លឹក<br>- ផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានី និងតាមបណ្ដាខេត្តក្រុងទាំង៨ភូមិភាគចំនួន៩០៦នាក់ ស្មើនឹង៧៨លើក និងទូទាត់ការជួសជុលរថយន្តចំនួន១៣លើក<br>- ផ្ដល់សេវាថវិកាជូនថ្នាក់ដឹកព្រឹទ្ធសភា និងថ្នាក់ |

| | |
|---|---|
| សំណេះសំណាលជាមួយប្រជាពលរដ្ឋ និង ក្រុមប្រឹក្សាឃុំ នៅខេត្តព្រៃវែង បាត់ដំបង កំពង់ធំ ស្ទឹងត្រែង ក្រចេះ ព្រះវិហារ និង រាជធានីភ្នំពេញ<br>- ក្រុមសមាជិកាព្រឹទ្ធសភា បានរៀបចំវេទិកា ស្តីពីវឌ្ឍនភាពស្ត្រីក្នុងវិស័យនយោបាយ នៅព្រឹទ្ធសភា<br>- ក្រុមសមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញចុះប្រមូលព័ត៌មាន និងជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ នាយករដ្ឋបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ មេប៉ុស្តិ៍ចំនួន០៤លើក នៅខណ្ឌទួលគោក ខណ្ឌច្បារអំពៅ ខណ្ឌសែនសុខ និងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទី៣ ទី៤ និងទី៨ អញ្ជើញចុះប្រមូលព័ត៌មាន ចំនួន១៥ឃុំ ក្នុងខេត្តកំពង់ចាម និងចុះស្រាវជ្រាវពីបញ្ហាប្រឈម សំណូមពរថ្មីៗ នៅស្រុកកៀនស្វាយ ដើម្បីត្រៀមលក្ខណៈក្នុងការរៀបចំវេទិកាថ្នាក់ស្រុកនាពេលខាងមុខ និងបានចុះទៅសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៃស្រុកសំឡូត ខេត្តបាត់ដំបង ព្រមទាំងចុះតាមដានលទ្ធផល និងឈ្វេងយល់ពីវឌ្ឍនភាពក្រោយវេទិកា នៅខេត្តរតនគិរី ខេត្តស្ទឹងត្រែង ខេត្តក្រចេះ និងខេត្តព្រះវិហារ<br>- ក្រុមសមាជិកភូមិភាគទី៣ បានអញ្ជើញ | ដឹកនាំអគ្គលេខាធិការដ្ឋាន ព្រមទាំងមន្ត្រីរាជការ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៦៥លើក ព្រមទាំងទូទាត់ថ្លៃទិញអង្ករចំនួន១០តោន និង ថ្លៃទិញវត្ថុអនុស្សាវរីយ៍<br>- ទទួលលិខិតចូលចំនួន៥៨១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៩៥ច្បាប់<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗ ចំនួន១៥នាក់ ស្មើនឹង០៤លើក<br>- ផ្តល់រូបថតចំនួន២.១១០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន៤៣អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូអ្នកដឹកនាំវ័យក្មេងមកពីតំបន់អាស៊ី និងសហរដ្ឋអាមេរិក លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មកពីសាកលវិទ្យាល័យនានាចំនួន០៣លើក<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៤២នាក់ ធ្វើប័ណ្ណសមាជិកចំនួន១៣រូប ខ្ចីសៀវភៅចំនួន៥៣ក្បាល និងសងវិញចំនួន៥០ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សា លោកគ្រូ អ្នកគ្រូ និងនិស្សិត មកពីវិទ្យាល័យមិត្តភាព-វៀតណាម ព្រះពន្លា ខេត្តស្វាយរៀង, សាកលវិទ្យាល័យ Southeast Asia ខេត្តសៀមរាប និងមន្ត្រីស្រាវជ្រាវសម្រាប់ដំណាក់កាលទី២ សរុបចំនួន០៣លើក មានអ្នកចូលរួមចំនួន៨០នាក់ |

| | |
|---|---|
| ចុះប្រគល់ម៉ាស៊ីនបូមទឹក ចំនួន០១គ្រឿង ជូនឃុំព្រៃលាស់ និងជួបសំណេះសំណាល ជាមួយក្រុមប្រឹក្សាឃុំដំណាក់អំពិល ដើម្បី ពិនិត្យចំនួនប្រជាពលរដ្ឋ ដែលបានចុះ ឈ្មោះបោះឆ្នោតរួចហើយ និងបន្តជំរុញ ផ្សព្វផ្សាយបន្ថែមទៀតនៅខេត្តកណ្តាល<br>- គណៈប្រតិភូព្រឹទ្ធសភា និងជាតំណាង សម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញ ចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម ហ៊ុល សារ៉ន្ត អតីតសមាជិករដ្ឋសភាមណ្ឌល ខេត្តស្វាយរៀង និងឯកឧត្តម រុង ផ្លាម កេសន អតីតសមាជិកព្រឹទ្ធសភា នីតិកាល ទី១ និងអតីតជាអភិបាលខេត្តកោះកុង<br>- ឯកឧត្តមអគ្គលេខាធិការតំណាងដ៏ខ្ពង់ ខ្ពស់សម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញ នាំយកបច្ច័យទៅប្រគេនព្រះចៅអធិការ វត្តកប់ស្រូវ ដើម្បីធ្វើផ្លូវបេតុងធ្នឹងដែកចំនួន ០១ខ្សែ ប្រវែង២៥០ម៉ែត្រ នៅក្នុងវត្តកប់ ស្រូវ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជ ធានីភ្នំពេញ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញ ចូលរួមសិក្ខាសាលាស្តីពី បទពិសោធន៍នៃ ដំណើរការរៀបចំថវិកា ក្នុងបរិបទប្រទេស និយាយភាសាបារាំង ច្បាប់ហិរញ្ញវត្ថុ ថវិកា ថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកា<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន០១ករណី ធ្វើលិខិតអន្តរាគមន៍ផ្ញើជូន | - ទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាសែតពីអង្គការ ស្ថានទូត ស្ថាប័ន ក្រសួង គ្រឹះស្ថានអប់រំ សប្បុរសជន នាយកដ្ឋានចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១២១ក្បាល និង៥២ច្បាប់<br>- ទទួល និងធ្វើកំណត់បង្ហាញពាក្យបណ្តឹងប្រជា ពលរដ្ឋចំនួន១០ករណី និងធ្វើកំណត់បង្ហាញ លិខិតបំភ្លឺមកពីក្រសួង-ស្ថាប័ន ជូនថ្នាក់ដឹកនាំ ចំនួន០៤ច្បាប់ៗ |

| | |
|---|---|
| ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយបានចំនួន០២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នមានសមត្ថកិច្ចបានចំនួន០៣ករណី និងឆ្លើយតបទៅម្ចាស់បណ្ដឹងបានចំនួន០២ករណី តំកល់ទុកមិនចាត់ការចំនួន០២ករណី ព្រមទាំងទទួលពាក្យបណ្ដឹងជូនជ្រាបចំនួន ១១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត រាជធានី ទូទាំងប្រទេស ចំនួន១៦៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ពិសេសផ្សព្វផ្សាយ និងជំរុញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៨៨លើក ។ | |

## ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អនុញ្ញាតឲ្យប្រធានរដ្ឋសភា និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ឯកអគ្គរដ្ឋទូតចិន ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ គណៈប្រតិភូយុវជននៃសមាគមនារីយុវជន និងគណៈប្រតិភូយុវជនកម្ពុជាក្នុងកម្មវិធី អ្នកដឹកនាំវ័យក្មេងអាស៊ាន ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីប្រគល់ និងទទួលកុំព្យូទ័រចំនួន៣៦គ្រឿង<br>- ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា អនុញ្ញាតឲ្យគណៈប្រតិភូជាន់ខ្ពស់នៃសភាប្រឹក្សានយោបាយចិន ដឹកនាំដោយឯកឧត្តម វ៉ាង រ៉ុង ប្រធានគណៈកម្មាធិការសភាប្រឹក្សានយោបាយប្រជាជនចិន ខេត្តក្វាងទុង ចូលជួបសម្តែងការគួរសម<br>- ឯកឧត្តមប្រធានស្តីទីគណៈកម្មការទី១ បានអញ្ជើញជួបពិភាក្សាការងារជាមួយភារធារីស្ថានទូតជប៉ុនប្រចាំកម្ពុជា និងតំណាងវិទ្យាស្ថានសភាកម្ពុជា PIC ស្តីពីការបណ្តុះបណ្តាលកម្មសិក្សាការី នៃការិយាល័យថវិកាសភា PBO<br>- លោកជំទាវប្រធានគណៈកម្មការទី៨ បាន | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៣៥ និងចូលរួមកិច្ចប្រជុំសភាសមាគមអគ្គលេខាធិការពិភពលោក (ASGP) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាផ្គត់ផ្គង់សម្ភារ ភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗ ចំនួន១២លើក អ្នកចូលរួមចំនួន៤៦១នាក់<br>- ថតចម្លងឯកសារ និងចងក្រងធ្វើសៀវភៅចំនួន១៥សំណើ(៤១៥ច្បាប់) សៀវភៅចំនួន១០ក្បាល អស់ក្រដាសចំនួន១២.០២៤សន្លឹក<br>- ផ្តល់សេវាថវិកា សម្ភារ និងភេសជ្ជៈ សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីព្រឹទ្ធសភា ព្រមទាំងបានទូទាត់ថ្លៃចំណាយផ្សេងៗចំនួន១៦លើក<br>- ផ្តល់សេវាដឹកជញ្ជូនជូនមន្ត្រីរាជការព្រឹទ្ធសភាក្នុងរាជធានីចំនួន៣៥រូប ស្មើនឹង២០លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ កម្មវិធីទស្សនកិច្ច និងធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញជូន និងទទួលដំណើរបេសកកម្មសរុបចំនួន១២លើក |

| | |
|---|---|
| អញ្ជើញជួបពិភាក្សាការងារជាមួយតំណាង Max Planck Foundation<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភាលើកទី១៣៩ កិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅប្រទេសស្វីស ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារក្នុងការអភិវឌ្ឍអាជីវកម្មនៅប្រទេសហូឡង់ និងទស្សនកិច្ចសិក្សាអំពីការងារសង្គម ការងារមនុស្សធម៌ ព្រមទាំងជួបសំណេះសំណាលជាមួយពាណិជ្ជករចំនួន៥០រូប នៅប្រទេសម៉ាឡេស៊ី។ | - បង្ហោះកម្មវិធីលើទូរទស្សន៍នៅតាមអគារ E, F, G,ចំនួន២០លើក លើបណ្តាញសង្គម Facebook ចំនួន១២៨លើក តាមស្ថានីយ៍ទូរទស្សន៍ចំនួន០៩លើក<br>- បន្តទំនាក់ទំនង ដើម្បីពង្រឹងកិច្ចសហប្រតិការជាមួយដៃគូជាតិ អន្តរជាតិ ផ្លាស់ប្តូរបទពិសោធន៍ ទស្សនកិច្ចសិក្សាលើជំនាញ IT ជំនាញបណ្ណាល័យ និងភាសាអង់គ្លេសសម្រាប់មន្រ្តីរាជការ<br>- ចេញលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៧រូប ស្មើនឹង១១ច្បាប់ និងបញ្ជូនទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន១៦ច្បាប់<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧រូប ស្មើនឹង០៦លើក<br>- សហការជាមួយអង្គការមូលនិធិ Max Planck អន្តរជាតិ, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOICA និងអង្គការមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ KAS និងក្រសួងយុត្តិធម៌ រៀបចំសិក្ខាសាលាចំនួន០៣លើក ស្តីពី " កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ-យន្តការត្រួតពិនិត្យអន្តរជាតិ, កាតព្វកិច្ចសន្ធិសញ្ញាអន្តរជាតិ-តុលាការអន្តរជាតិ និងសេចក្តីផ្តល់នៃការតាក់តែងច្បាប់ ឯកសារយោង និងបច្ចេកទេស "<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សភារ៉ូឡូទីព្រុចសែល ប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការនិយាយភាសាបារាំង |

| | |
|---|---|
| | សង្គមស៊ីវិល ក្រសួងនិងស្ថាប័ននានា សម្រាប់ដំណើរទេសចរណ៍កិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ព្រឹទ្ធសភាកំពុងដំណើរការសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន<br>- សហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន ។ | - បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦៩ច្បាប់<br>- រៀបចំចងក្រងបទបង្ហាញស្តីពីលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០១៦ និងរបាយការណ៍ស្តីពីលទ្ធផលការងាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រង់ស្ថិតិស្តីពីលទ្ធផលការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាគណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០១៦ ព្រមទាំង បានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះសរុបចំនួន២៧០ច្បាប់<br>- បញ្ចូលទិន្នន័យសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា និងកាលប្បវត្តិ-ឯកសារទៅក្នុងប្រព័ន្ធកុំព្យូទ័របានចំនួន១៥ច្បាប់ ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- ធ្វើកំណត់បង្ហាញជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ស្នើសុំសេចក្តីសម្រេចលើគោលការណ៍ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការទៅសិក្សានៅក្នុង-ក្រៅប្រទេស និងស្នើសុំការអនុញ្ញាតជាអធិបតីក្នុងពិធីបំពាក់ |

| | |
|---|---|
| | គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការដែលមានស្នាដៃសម្រាប់ឆ្នាំ២០១៥ ចំនួន៧២នាក់ នៅដើមខែវិច្ឆិកា ឆ្នាំ២០១៦<br>- បានធ្វើលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣៦ច្បាប់<br>- ប្រជុំអន្តរគណៈកម្មការពាក់ព័ន្ធនឹងវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។<br>**+ការងារបណ្តុះបណ្តាលធនធានមនុស្សៈ**<br>- បណ្តុះបណ្តាលធនធានមនុស្សនៅក្នុង-ក្រៅស្ថាប័នចំនួន១០វគ្គ មានសិក្ខាកាមសរុបចំនួន១៦២នាក់ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ០៣វគ្គ មានសិក្ខាកាមចំនួន០៣នាក់<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២២)។<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- បានរៀបចំរបាយការណ៍ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា អំពីគម្រោងថវិកាឆ្នាំ២០១៧ក្រោយការពារថវិកាក្នុងកម្រិតនយោបាយ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែតុលា ឆ្នាំ២០១៦ ផ្ញើជូនក្រសួងសេដ្ឋកិច្ច |

| | |
|---|---|
| | និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ជួសជុលរថយន្ត កែលម្អសោភ័ណ្ឌភាពសួនច្បារ អគារ សាលប្រជុំ ផ្លូវថ្នល់នៅក្នុងបរិវេណព្រឹទ្ធសភា និងទូទាត់ការបោះពុម្ពសៀវភៅ និងឯកសារផ្សេងៗចំនួន៥៤លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន៣៧សំណើ ព្រមទាំងបានប្រគល់ និងទទួលសម្ភារផ្សេងៗចំនួន០៦សំណើ ផ្គត់ផ្គង់សម្ភារអនាម័យ ការិយាល័យ និងភេសជ្ជៈចំនួន៤២សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន១៤លើក មានអ្នកចូលរួមចំនួន៤០៣នាក់<br>- បានឧបត្ថម្ភ និងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន៦៦លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៤៥សំណើ(២.៦៩៨ច្បាប់) ធ្វើសៀវភៅ៤៣ក្បាល អស់ក្រដាសចំនួន ១៨,៧៣៧សន្លឹក និងជួសជុល លាងសំអាតម៉ាស៊ីនថតចម្លងចំនួន១០លើក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត-ក្រុងទាំង៨ |

| | |
|---|---|
| | ភូមិភាគចំនួន០៣លើក មានអ្នកចូលរួម១៨នាក់ និងផ្តល់សេវាដឹកជញ្ជូនក្នុងរាជធានីភ្នំពេញចំនួន ១១៦លើក អ្នកចូលរួម២២០នាក់ ។<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:**<br>- កាត់តម្រឹមស្មៅ ផ្កា ថែទាំដាក់ជី ដាំដើមឈើផ្សេងៗ និងលើកដីដាំស្មៅនៅតាមជម្រាលរបង ខាងមុខព្រឹទ្ធសភា ព្រមទាំងថែទាំសួនច្បារនានា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- សហការស្តារប្រព័ន្ធលូ ដាក់លូថ្មីនៅក្នុងបរិវេណការដ្ឋានសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- ខាត់លាបស្នាមប្រឡាក់នៅសាលបណ្ណាល័យ លាបថ្នាំឡើងវិញរបងសំណាញ់ និងរបងថ្មនៅជុំវិញព្រឹទ្ធសភា<br>- សហការចុះត្រួតពិនិត្យសត្វកណ្តៀរ នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សាលប្រជុំពេញអង្គ ការិយាល័យអគ្គលេខាធិការ និងអគារB<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចសរុបចំនួន១០៩គ្រឿង ជួសជុលបណ្តាញទឹកចំនួន០៥ខ្សែ និងជួសជុលកែលម្អបន្ទប់ទឹកនៅខាងក្រោយសាលបណ្ណាល័យ និងក្រោយសាលពិសេស<br>- បិទលេខកូដតុ កៅអី ម៉ាស៊ីនត្រជាក់ និងUPS ចំនួន២៨គ្រឿង<br>- សហការរៀបចំ និងប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំចំនួន១៩លើក |

| | |
|---|---|
| | - ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន១២៤គ្រឿង។<br>- សង់ឃ្លាំងប្រក់ដំបូលស័ង្កសីដាក់សម្ភារនៅក្រោយអគារD ប្តូរដំបូលអគារមូលនិធិ និងដំបូលក្រោយសាលពិសេសធំ ព្រមទាំងចាក់សាបនៅក្រោយអគារជប៉ុន និងរៀបជញ្ជាំងថ្មភ្នំចាប់ពីច្រកទ្វារ P1 ដល់រោងចំណតរថយន្តក្រោមដើមជ្រៃ ។<br>+ការងារផ្សេងៗ:<br>- រៀបចំ និងចងក្រងសៀវភៅជាភាសាអង់គ្លេស ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មីសរុបចំនួន៩០ក្បាល<br>- បញ្ចូលសៀវភៅតាម PMB និងបញ្ចូលឯកសារសៀវភៅច្បាប់តាម E-Library សរុបចំនួន ៤៤៦ក្បាល ដែលមានអ្នកចូលអានចំនួន ១៦៤នាក់<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន២៤លើក អស់កាសែត៣៨ដុំ និងស៊ីឌីចំនួន៣៦បន្ទះ<br>- បង្ហោះរបាយការណ៍លទ្ធផលការងារ និងរូបថតសកម្មភាពរបស់ថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំផ្សេងៗចំនួន១៥លើក។ ស្កេន ពិនិត្យអក្ខរាវិរុទ្ធ តម្លើងប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល និងដាក់កម្មវិធី software Check List<br>- សិស្ស និស្សិតចូលមកអានសៀវភៅនៅបណ្ណាល័យ |

| | |
|---|---|
| | ចំនួន៩៦នាក់ ភ្ញៀវមកទំនាក់ទំនងការងារក្នុងព្រឹទ្ធសភាចំនួន៥៤នាក់ មន្ត្រីចេញ ចូលថ្ងៃឈប់សម្រាកចំនួន២៩០នាក់<br>- ការពារ និងរៀបចំសណ្តាប់ធ្នាប់រថយន្តគ្រប់ប្រភេទនៅក្នុងបរិវេណព្រឹទ្ធសភាបានចំនួន២១លើក។ |

## II.ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០១៦

### ១.មុខងារនីតិកម្ម:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៣ (រំពឹងមកពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦)៖

+ សេចក្តីព្រាងច្បាប់ ស្តីពីការប្រែប្រួលធាតុអាកាស

+ សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៧

+ សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាជាតិឆ្នាំ២០១៥

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ និងបទបញ្ជាផ្ទៃក្នុងថ្មី។

### ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង ។

### ៣.មុខងារតំណាង :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា តាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគទាំង៨ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមរៀបចំកម្មវិធីបុណ្យឯករាជ្យជាតិ និងបុណ្យអុំទូក

### ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ជាពិសេសកម្មង់ទស្សនកិច្ចនៃគណៈប្រតិភូជាន់ខ្ពស់ចិន ព្រមទាំងពិធីទទួលសារតាំងទូតថ្មី

-ត្រៀមទទួលប្រធានព្រឹទ្ធសភារុស្ស៊ី និងអនុប្រធានព្រឹទ្ធសភាឥណ្ឌា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស៖

-ប្រទេសកូរ៉េខាងត្បូង ប៉ាគីស្ថាន អូស្ត្រាលី បារាំង

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO និង KOICA

-រៀបចំការបណ្តុះបណ្តាល PBO និងទំនាក់ទំនងជាមួយលេខាធិការដ្ឋាន APF អំពីកិច្ចសហប្រតិបត្តិការ បច្ចេកទេស

-ការបញ្ជូនមន្ត្រីចំនួន ០៧រូប ចូលរួមសន្និបាតវិទ្យាស្ថានKPI នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាល ខាងការស្រាវជ្រាវ ជំហានទី២ របស់វិទ្យាស្ថានសភាកម្ពុជា (PIC) ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ តាមប្រព័ន្ធព័ត៌មានវិទ្យាកសាង Program និង Software ដើម្បីអនុវត្តន៍តាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះការអនុវត្តកម្មវិធី E-បណ្ណាល័យ និង E-បណ្ណសារ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រកព កូរ៉េ ជប៉ុន ចិន ឥណ្ឌា អូស្ត្រាលី នូវែលហ្សេឡង់ សិង្ហបុរី ថៃ ម៉ាឡេស៊ី

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តជាក់ស្តែង

-ការរៀបចំបែងចែកគម្រោងថវិកាឆ្នាំ២០១៧ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការត្រៀមរបាយការណ៍ចំណូល - ចំណាយថវិកាឆ្នាំ២០១៦ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារ ICT ជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដំណាក់កាលទី២

-ការសិក្សារៀបចំ TV - online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអន្តរគណៈកម្មការពាក់ព័ន្ធនឹងវិសោធនកម្មច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិបំរើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

- ត្រៀមកសាងប្រទីប ដើម្បីចូលរួមអបអរពិធីបុណ្យអុំទូក (ថ្ងៃទី១៣,១៤,១៥ ខែវិច្ឆិកា ឆ្នាំ២០១៦) និងត្រៀមការបោះពុម្ពបំណាច់ឆ្នាំ

- ត្រៀមធ្វើជំរឿនមន្ត្រីរាជការ បុគ្គលិកជាប់សន្យា និងអ្នកហាត់ការ ជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងជំរឿនធនធានមនុស្ស

- រៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ

- កសាងបង្គន់អគារសាលប្រជុំចាស់ ថ្មី និងការរៀបចំជុំវិញបរិវេណអគារការិយាល័យថ្នាក់ដឹកនាំ ព្រមទាំងត្រៀមឯកសារពាក់ព័ន្ធដល់ការសម្ពោធអគារ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមរៀបចំពិធីសែនក្រុងពាលី សូត្រមន្ត និងដង្ហែកឋិនទាន រួមទាំងពិធីផ្សេងៗទៀតជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានយ៉ាងល្អប្រសើរ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០១លើក ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចុះតាមដានប្រមូលព័ត៌មាន នៅខេត្តកំពង់ចាម និងព្រៃវែង ។ ដោយឡែក លើមុខងារតំណាងបានចាត់ចែងកម្មវិធីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និវត្តន៍ជន អ្នកគ្រប់គ្រងស្ថានីយ៍ អ្នករត់ម៉ូតូឌុប ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសព និងពិធីផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តព្រៃវែង បាត់ដំបង កំពង់ធំ ស្ទឹងត្រែង ក្រចេះ កោះកុង និងខេត្តព្រះវិហារ ។ល។ ការអភិវឌ្ឍស្ថាប័ន បានឆ្លុះបញ្ចាំងឲ្យឃើញនូវការអភិវឌ្ឍធនធានមនុស្ស ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ការកសាងអគារ និងហេដ្ឋារចនាសម្ព័ន្ធមានការរីកចម្រើនលើគ្រប់វិស័យ ព្រមទាំងទទួលដំណើរទស្សនកិច្ចរបស់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មកកាន់ព្រឹទ្ធសភា ដើម្បីឲ្យយល់ដឹងអំពីដំណើរការវិវត្តការងាររបស់ព្រឹទ្ធសភា បានអនុវត្តន៍ល្អ និងទូលំទូលាយជាងមុន។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា (PIC) និងដៃគូអភិវឌ្ឍន៍នានា។

ភ្នំពេញ,ថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**អ៊ុំ.សារឹទ្ធ**